**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...០៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងអង្គភាពផលិតភាពទៅជាមជ្ឈមណ្ឌលផលិតភាពជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សម្រេច

**មាត្រា១ :** ត្រូវបានដំឡើងអង្គភាពផលិតភាព នៃនាយកដ្ឋានកិច្ចការឧស្សាហកម្មទៅជាមជ្ឈមណ្ឌលផលិតភាពជាតិ ថ្នាក់ស្មើនាយកដ្ឋាន ចំណុះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា២ :** មជ្ឈមណ្ឌលផលិតភាពជាតិ មានតួនាទី និងភារកិច្ច ដូចតទៅ :

- បំពេញភារកិច្ច និងអនុវត្តកាតព្វកិច្ច នៃសមាជិកអង្គការផលិតភាពអាស៊ី
- ទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការផលិតភាពជាតិ នៃប្រទេសនានា
- គ្រប់គ្រង សម្របសម្រួល និងជំរុញចលនាផលិតភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ក្នុងទិសដៅអភិវឌ្ឍន៍វិស័យផលិតភាព សម្រាប់សេដ្ឋកិច្ចសង្គមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ផ្តល់យោបល់អំពីគោលនយោបាយ និងកម្មវិធីលើកកំពស់ផលិតភាព គុណភាព និងប្រសិទ្ធភាពការងារ សម្រាប់សកម្មភាពថ្នាក់ជាតិ
- ផ្តល់យោបល់អំពីគោលដៅផលិតភាពជាតិ ក្នុងការបង្កើតផែនការអភិវឌ្ឍន៍ជាតិ
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ដើម្បីជំរុញលើកកំពស់ផលិតភាពការងារ
- រៀបចំបង្កើត និងលើកសំណើអំពីនីតិវិធី បទដ្ឋាន នៃទស្សនៈផលិតភាពទៅតាមនិន្នាការ និងការិតអភិវឌ្ឍន៍ នៃស្ថានភាពសេដ្ឋកិច្ច-សង្គម
- ធ្វើការផ្តល់សេវាកម្ម ពិគ្រោះយោបល់ និងបណ្តុះបណ្តាលលើផ្នែកផលិតភាព
- ជំរុញ និងគាំទ្រការបង្កើតសហគ្រាសពិគ្រោះយោបល់ឯកជន លើផ្នែកគ្រប់គ្រងផលិតភាពផលិតកម្ម និងសេវាកម្ម
- រៀបចំជំរុញការងារផ្លូវផ្តងការិតផលិតភាពរបស់សហគ្រាសឯកជន ដើម្បីបង្កើនល្បឿនលើកកំពស់ផលិតភាព
- ធ្វើការអភិវឌ្ឍន៍ផលិតភាព និងគុណភាព ជាពិសេសវប្បធម៌ផលិតភាព ដើម្បីលើកកំពស់សមត្ថភាពប្រកួតប្រជែង
- សហការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីរៀបចំគំរោង និងអនុវត្តគំរោងអភិវឌ្ឍន៍ផលិតភាព
- សហការជាមួយអង្គការផលិតភាពអាស៊ី ដើម្បីផ្តល់ការលើកទឹកចិត្តដល់អង្គភាព ឬអ្នកមានស្នាដៃលើការងារផលិតភាព
- ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាផលិតភាពជាតិ
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង រៀបចំស្ថិតិ សន្ទស្សន៍ផលិតភាព និងផ្សព្វផ្សាយឯកសារព័ត៌មានផលិតភាព ។

**មាត្រា៣ :** មជ្ឈមណ្ឌលផលិតភាពជាតិដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា៤ :** រចនាសម្ព័ន្ធព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលផលិតភាពជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា៥ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រីសូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ស៊ុយ សែម**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- កាលប្បវត្តិ-ឯកសារ